អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
## លោកស្រី ក្លូឌៀ ហ្វិន ត្រូវបានតែងតាំង ជាចៅក្រមអន្តរជាតិថ្មីនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក

បន្ទាប់ពីទទួលបាននូវការចាត់តាំងពីឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ និងទទួលការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម **ព្រះករុណា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានតែងតាំងលោកស្រី ក្លូឌៀ ហ្វិន (ជនជាតិអូទ្រីស) ជាចៅក្រមអន្តរជាតិថ្មីនៃអង្គជំនុំជម្រះ សាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ការតែងតាំងនេះមានសុពលភាពចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០១៤ នេះតទៅ។ លោកស្រីចៅក្រម ក្លូឌៀ ហ្វិន បានបម្រើការងារជាចៅក្រមអន្តរជាតិបម្រុងនៅអង្គជំនុំជម្រះសាលាដំបូងចាប់តាំងពីឆ្នាំ ២០០៦ មកម្ល៉េះ ហើយលោកស្រីជំនួសលោកស្រីចៅក្រម ស៊ីលវៀ ខាត់វ៉ាយត៍ (ជនជាតិនូវែលហ្សេឡង់) ដែលការលាលែងពីតំណែងរបស់លោកស្រីចូលជាធរមាននៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០៤ នេះ។

លោកស្រីចៅក្រម ក្លោឌៀ ហ្វិន បានទទួលសញ្ញាប័ត្របណ្ឌិតច្បាប់ពីសាកលវិទ្យាល័យក្រុងវីយែន។ នៅឆ្នាំ១៩៨៤ លោកស្រីបានទទួលការតែងតាំងជាចៅក្រមនៅក្នុងប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌប្រចាំប្រទេស និងបានកាន់តំណែងនេះអស់រយៈពេលជាង២០ឆ្នាំដោយធ្វើការនៅផ្នែកស៊ើបអង្កេត នៅអង្គជំនុំជម្រះសាលាដំបូង និងនៅសាលាឧទ្ធរណ៍។ នៅឆ្នាំ២០០៤ លោកស្រី ត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិ សម្រាប់បេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ ទាក់ទិននឹងឧក្រិដ្ឋកម្មដែលមានរចនាសម្ព័ន្ធចាត់តាំង ឧក្រិដ្ឋកម្មដែលមានចរិតលក្ខណៈជាតិពន្ធុ និងឧក្រិដ្ឋកម្មសង្គ្រាម។ បន្ទាប់មកលោកស្រី ធ្វើការងារជាប្រធានផ្នែកនីតិរដ្ឋនៅក្នុងបេសកកម្ម EUPOLCOPPS នៅប៉ាឡេស្ទីន ដែលផ្តល់ការគាំទ្រដល់ផ្នែកនគរបាល និងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌប៉ាឡេស្ទីន (ឆ្នាំ២០០៦-២០០៨)។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

**លោក ឡាស អូលសិន**
មន្ត្រីច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh